ភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៣

# សេចក្តីសំរេច លេខ ២៥ សសរ ស្តីពីការបង្កើត ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

x x x

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់ សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- ផ្អែកតាមតំរូវការចាំបាច់

## សំរេច

ប្រការ ១ : បង្កើតក្រុមប្រឹក្សាជាន់ខ្ពស់មួយឈ្មោះថា " ក្រុមប្រឹក្សាជាន់ខ្ពស់ ផ្នែកវប្បធម៌ជាតិ " ដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ ទេសរដ្ឋមន្ត្រី ប្រធាន

២- ឯកឧត្តម នុត ណារ៉ាំង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុប្រធាន

៣- ព្រះអង្គម្ចាស់ នរោត្តម សិរីវុឌ្ឍ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការ ឬ តំណាង សមាជិក

៤- ឯកឧត្តម អេង រ៉ូឡង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង សមាជិក

៥- ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬ តំណាង សមាជិក

៦- ឯកឧត្តម ជា ចាន់តូ រដ្ឋមន្ត្រីក្រសួងផែនការ ឬ តំណាង សមាជិក

៧- ឯកឧត្តម សម រង្ស៊ី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ឬ តំណាង សមាជិក

៨- ឯកឧត្តម មីសែល ត្រាណេ អនុរដ្ឋមន្ត្រីក្រសួង វប្បធម៌និងវិចិត្រសិល្បៈ សមាជិករាយការណ៍

៩- ឯកឧត្តម អភិបាលខេត្តសៀមរាប សមាជិក

១០- លោក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

ប្រការ ២ : ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ មានសិទ្ធិអញ្ជើញ ឯកឧត្តម អស់លោករដ្ឋមន្ត្រី តំណាងសភាជាតិ តំណាង ស្ថាប័នជាតិ និង អន្តរជាតិ ដែលមានការពាក់ព័ន្ធទៅនឹងការ

ងារវប្បធម៌ជាតិអោយចូលមកប្រជុំ ពិភាក្សាតាមករណីចាំបាច់ក្នុងនោះ សូមអញ្ជើញជាពិសេស :

- នាយក Ecole Française d'Extrême Orient ឬ តំណាង ប្រទេសបារាំង
- នាយក Institute of Asian Cultures ( Sophia University ) ឬតំណាង ប្រទេសជប៉ុន
- នាយក World Monument Fund ឬតំណាង សហរដ្ឋអាមេរិក
- ឥស្សរជនជំនាញជាន់ខ្ពស់ជាតិ និង អន្តរជាតិ ។

**ប្រការ ៣ :** ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិមានភារកិច្ចដូចតទៅ ÷

ក- ពិនិត្យបញ្ចូលជាបេតិកភ័ណ្ឌវប្បធម៌ជាតិ ក្នុងនោះមានតំបន់រមណីយដ្ឋាននិងប្រាសាទជាប្រវត្តិសាស្ត្រ ។

ខ- ការពារការលស់សម្បត្តិវប្បធម៌ បុរាណ និង ប្រវត្តិសាស្ត្រមានលក្ខណៈជារួបិយ ។

គ- គ្រប់គ្រង និង ត្រួតពិនិត្យតំបន់ប្រាសាទដែលបានកំណត់ទុក និង វត្ថុសិល្បៈមាននៅទីនោះ ។

ឃ- ផ្តល់ការអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវវត្ថុបុរាណ ការថែរក្សា និង ធ្វើអន្តរាគមន៍ដទៃណាពាក់ព័ន្ធដល់រាល់តំបន់ប្រាសាទ និង សម្បត្តិវប្បធម៌ជាតិ ។

ង- គ្រប់គ្រងដល់តំបន់ជាប្រវត្តិសាស្ត្រនេះ ដើម្បីការពារបេតិកភ័ណ្ឌជាតិត្រូវ ÷

- រៀបចំនយោបាយលើកតំលៃបេតិកភ័ណ្ឌ
- រៀបចំទូលាយជូនសាធារណជនទស្សនា
- រៀបចំក្របខ័ណ្ឌទទួលបន្ទុកក្នុងការងារនេះ
- រៀបចំប្រព័ន្ធទេសចរណ៍

ច- ផ្សព្វផ្សាយតំលៃវប្បធម៌ ស្វែងរកមូលនិធិ បង្រៀនប្រជារាស្ត្រ ហ្វឹកហ្វឺន និងធ្វើការស្រាវជ្រាវពាក់ព័ន្ធបេតិកភ័ណ្ឌជាតិ និង ប្រវត្តិសាស្ត្រជាតិ ដែលមានភាពជារួបិយ ។

ឆ- ធានាការទទួលខុសត្រូវ និង ករណីយកិច្ចគ្រប់គ្រងជាមួយកិច្ចព្រមព្រៀងផ្នែកវប្បធម៌ និង បណ្តាគន្លងទាំងឡាយដែលរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា ។

ជ- ធានាបានការចាំបាច់ដើម្បី អនុវត្តអោយបានល្អ ការគ្រប់គ្រងតំរោង និង ការងារពាក់ព័ន្ធទៅនឹងការពារថែរក្សា ស្តារ និង លើកតំលៃបេតិកភ័ណ្ឌជាតិ ។

ប្រការ ៤ : សមាជិកទាំងអស់ នៃក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវ ចូលរួមធ្វើការងារតាម សេចក្តីអញ្ជើញ និង ការណែនាំរបស់ប្រធាន ។

ប្រការ ៥ : ប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវរៀបចំលេខាធិការដ្ឋានមួយ ជាអចិន្ត្រៃយ៍ ដែលមានទីតាំងនៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ប្រការ ៦ : ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង អភិបាលខេត្តសៀមរាប ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

ប្រការ ៨ : សេចក្តីសំរេចណាដែលមានន័យផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា និង ត្រា　　　　ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ　　　　ហ៊ុន សែន

* * * *